Component A

AHIF Grant No. TF056832, PRHD Grant No. TF058146, IDA Grant No. H3610-KH

គម្រោងលេខ: IDA Grant No. H3610-KH and AHIF Grant No. TF058146

គម្រោងគ្រប់គ្រង និងទប់ស្កាត់បន្ទាន់ជំងឺផ្តាសាយបក្សី និងផ្តាសាយមនុស្ស

# សៀវភៅណែនាំ
## ស្តីពី
# វិធានជីវសុវត្ថិភាព
# លើការអភិវឌ្ឍន៍បច្ចេកវិជ្ជាចិញ្ចឹមបក្សី
# ជាលក្ខណៈពាណិជ្ជកម្ម



**នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល**

**ខែ ធ្នូ ឆ្នាំ ២០១២**

# មាតិកា


**សេចក្តីផ្តើម**............................................................................................................១

**១. ប្រព័ន្ធនៃការចិញ្ចឹមបក្សីជាលក្ខណៈពាណិជ្ជកម្ម នៅព្រះរាជាណាចក្រកម្ពុជា**.....២

១.១ ការចិញ្ចឹមបក្សីពាក់កណ្តាលលែង ឬលែងដោយសេរី (ឃ្វាលតាមវាល)........................២

១.២ ការចិញ្ចឹមបក្សីដាក់ទ្រុង ..............................................................................................២

**២. តើមេរោគចម្លងចូលកសិដ្ឋានដោយរបៀបណា**?..................................................................៣

**៣. តើត្រូវការពារ និងទប់ស្កាត់ជំងឺបក្សី ដោយរបៀបណា**? .............................................. ៦

**៣.១ វិធានជីវសុវត្ថិភាព** ....................................................................................... ៦

៣.១.១ វិធានជីវសុវត្ថិភាពជាប្រចាំ ....................................................................................... ៦

ក. ការដាក់ឲ្យនៅដាច់ដោយឡែក និងការត្រួតពិនិត្យចរាចរណ៍ .................................. ៦

ខ.ការសម្អាត ...................................................................................................................១៣

គ. ការបាញ់ថ្នាំរម្ងាប់មេរោគ ..........................................................................................១៥

ឃ. ការត្រួតពិនិត្យសត្វចង្រៃ និងសត្វដទៃទៀត ...........................................................១៧

ង. ដុត ឬ កប់សាកសពបក្សី............................................................................................១៨

ច. ការកត់ត្រា ..................................................................................................................១៨

ឆ. ការរាយការណ៍បក្សីឈឺ ឬ ងាប់ ....................................................................................១៨

៣.១.២ វិធានជីវសុវត្ថិភាពពេលមានគ្រោះថ្នាក់ខ្ពស់ ...........................................................១៩

**៣.២ ការចាក់វ៉ាក់សាំង និងការប្រើប្រាស់ថ្នាំព្យាបាល សម្រាប់ការពារ**..............១៩

**ឯកសារយោង** ............................................................................................................២២

# អារម្ភកថា

សៀវភៅណែនាំស្តីពី "**វិធានជីវសុវត្ថិភាព លើការអភិវឌ្ឍន៍បច្ចេកវិជ្ជាចិញ្ចឹមបក្សី ជាលក្ខណៈពាណិជ្ជកម្ម**" ត្រូវបានចងក្រងឡើងដោយផ្អែកលើបទពិសោធន៍ជាក់ស្តែង និងការបន្ថែមនូវបច្ចេកវិជ្ជាថ្មីៗនៃជីវសុវត្ថិភាព ព្រមទាំងមានការផ្តល់នូវយោបល់ល្អៗពីសំណាក់លោកនាយកគម្រោង ប្រធានគម្រោង អ្នកបច្ចេកទេស និងអ្នកពាក់ព័ន្ធមួយចំនួន ដើម្បីធ្វើយ៉ាងណាឲ្យការអនុវត្តន៍ ប្រកបដោយប្រសិទ្ធិភាព។ សៀវភៅនេះនឹងជួយផ្តល់នូវចំណេះដឹងជាមូលដ្ឋានស្តីពី **វិធានជីវសុវត្ថិភាព** ដល់អ្នកចិញ្ចឹមបក្សីយកសាច់ ស៊ុត និងទុកពូជ ជាលក្ខណៈពាណិជ្ជកម្ម ដើម្បីឲ្យផលិតកម្មបក្សីទទួលបានជោគជ័យ និងមាននិរន្តភាព។ ឯកសារនេះ គឺដើម្បីផ្តល់នូវវិធីសាស្រ្តងាយៗក្នុងការការពារ និងទប់ស្កាត់ការចម្លងរាលដាលនៃជំងឺបក្សី ពិសេសជំងឺផ្តាសាយបក្សី និងការពារសុខភាពសាធារណៈផងដែរ។ ទោះជាយ៉ាងនេះក្តី សៀវភៅនេះ នៅតែមានការខ្វះចន្លោះ ដែលទាមទារឲ្យមានការកែលំអថែមទៀត។ អាស្រ័យហេតុនេះ ការទិតៀនកែលំអក្នុងន័យស្ថាបនាពីសំណាក់អស់លោក លោកស្រី អ្នកបច្ចេកទេស និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវបានរង់ចាំទទួលដោយរីករាយ។

សៀវភៅនេះត្រូវបានចងក្រងដោយផ្អែកលើអនុសាសន៍ដ៏ថ្លៃថ្លា និងការចង្អុលបង្ហាញប្រកបដោយគតិបណ្ឌិតពី **ឯកឧត្តម បណ្ឌិត ចន្ទ័ សារុន** រដ្ឋមន្រ្តីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការណែនាំផ្តល់បច្ចេកទេសបន្ថែមពី **ឯកឧត្តម កៅ ផល** ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាលដោយរួមបញ្ចូលនូវបទពិសោធន៍ បច្ចេកទេសល្អៗជាច្រើន ពីក្រុមអ្នកជំនាញបច្ចេកទេស។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **លោក បណ្ឌិត ស៊ន សាន** នាយកគម្រោង **លោក ថន សុវីរ៉ា** ប្រធានគ្រប់គ្រងគម្រោង លោក លោកស្រី ទីប្រឹក្សា បច្ចេកទេសថ្នាក់ជាតិ លោក លោកស្រីប្រធាន អនុប្រធានការិយាល័យពាក់ព័ន្ធ នៃ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ការិយាល័យ ផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត អង្គការអន្តរជាតិ (FAO) និងស្ថាប័នពាក់ព័ន្ធ (NCDM) ដែលបានជួយផ្តល់ ជាគំនិត បទពិសោធន៍ ការសម្របសម្រួល និងសហការក្នុងការកែសម្រួលសៀវភៅណែនាំនេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាលកម្ពុជា និង ម្ចាស់ជំនួយធនាគារពិភពលោក ដែលបានផ្តល់មូលនិធិ សម្រាប់ការចងក្រង និងបោះពុម្ពសៀវភៅណែនាំនេះឡើង។

# សេចក្តីផ្តើម

បក្សីត្រូវបានចិញ្ចឹម ស្ទើរគ្រប់តំបន់នៅលើពិភពលោក ដោយការចំណាយទុនតិចជាងផលិតកម្មសត្វដទៃ ផ្តល់វដ្តផលិតកម្មឆាប់រហ័ស និងផ្តល់ទិន្នផលខ្ពស់។ នៅក្នុងអំឡុងទសវត្សន៍ចុងក្រោយនេះ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន បានអនុវត្តបច្ចេកវិជ្ជាចិញ្ចឹមបក្សីជាលក្ខណៈឧស្សាហកម្ម ដើម្បីផ្គត់ផ្គង់នូវតម្រូវការសាច់នៅលើទីផ្សារកើនឡើងយ៉ាងខ្ពស់ ដោយសារកំណើនយ៉ាងឆាប់រហ័សរបស់ប្រជាពលរដ្ឋ។

បក្សី (មាន់ ទា ទាកាប៉ា ក្រួច ក្ងាន ក្ងោក បក្សីហ្គីនេ (មាន់ចាប់ឡាក់) មាន់បារាំង) ត្រូវបានចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម នៅព្រះរាជាណាចក្រកម្ពុជា ចែកចេញជាពីរប្រភេទគឺ ការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មខ្នាតមធ្យម និងពាណិជ្ជកម្មខ្នាតធំ។ ផលិតកម្មបក្សីជាលក្ខណៈពាណិជ្ជកម្មខ្នាត មធ្យម មានការរីកចំរើនគួរឲ្យកត់សម្គាល់ ហើយការចិញ្ចឹមត្រូវបានបែងចែកជាការចិញ្ចឹមយកសាច់ ស៊ុត និងទុកពូជ។ សាច់ និង ស៊ុតបក្សី គឺជាប្រភពដ៏សំខាន់នៃប្រូតេអ៊ីន សារធាតុរ៉ែ និងវីតាមីន ដែលជាតម្រូវការចាំបាច់ នៅក្នុងរបបអាហារប្រចាំថ្ងៃរបស់មនុស្ស។ ម្យ៉ាងទៀតផលិតកម្មបក្សី បានចូលរួមចំណែកក្នុងការបង្កើននូវប្រាក់ចំណូលគ្រួសារ ដែលជាទិសដៅស្របតាមគោលនយោបាយ កាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

យោងតាមរបាយការណ៍បូកសរុបប្រចាំឆ្នាំ២០១០របស់នាយកដ្ឋានផលិតកម្មនិង បសុព្យាបាល បានបង្ហាញថា ស្ថិតិកសិដ្ឋានចិញ្ចឹមបក្សីជាលក្ខណៈពាណិជ្ជកម្មខ្នាតមធ្យម និងខ្នាតធំ ទូទាំងប្រទេសសរុបមានចំនួន ៨៨៧កសិដ្ឋាន ក្នុងនោះ កសិដ្ឋានចិញ្ចឹមមាន់យកសាច់ ស៊ុត មានចំនួន ៣០៧ កសិដ្ឋាន ចិញ្ចឹមទាផ្តល់សាច់ ស៊ុតមានចំនួន ៥៦៨ និងកសិដ្ឋានចិញ្ចឹមក្រួច ចំនួន ១២ កសិដ្ឋាន។ ទន្ទឹមនឹងនេះ តាមការកត់សម្គាល់ឃើញថា បក្សីចិញ្ចឹមលែងនៅតាមវាល ឬ បឹង អាចប៉ះពាល់ជាមួយបក្សីព្រៃ ឬ ប៉ះពាល់ជាមួយនឹងមេរោគ ដែលបន្សល់ពីហ្វូងបក្សីដទៃទៀតដែលមានជំងឺ។

សៀវភៅណែនាំស្តីពី **វិធានជីវសុវត្ថិភាព លើការអភិវឌ្ឍន៍បច្ចេកទេសចិញ្ចឹមបក្សី ជាលក្ខណៈពាណិជ្ជកម្ម** ត្រូវបានរៀបចំឡើងក្នុងគោលបំណងកែលំអរ និងបំពេញបន្ថែម ពីវិធានជីវសុវត្ថិភាពដល់អ្នកចិញ្ចឹមបក្សីយក សាច់ ស៊ុត និងទុកពូជ ជាលក្ខណៈពាណិជ្ជកម្ម ឲ្យទទួលបានជោគជ័យនៅក្នុងផលិតកម្ម និងមាននិរន្តភាព។ វិធានជីវសុវត្ថិភាពទាមទារនូវការអនុវត្តជាប្រចាំ ដើម្បីជារបាំងសម្រាប់ការពារ និងទប់ស្កាត់ការចម្លងរមេរោគចូលក្នុងកសិដ្ឋាន និង រីករាលដាលទៅកសិដ្ឋានចិញ្ចឹមបក្សីដទៃ។ ការអនុវត្តជីវសុវត្ថិភាពបានត្រឹមត្រូវ អាចការពារទាំងសុខភាពសត្វ និងសុខភាពមនុស្ស ជៀសផុតពីការចម្លងជំងឺផ្សេងៗ ពិសេសជំងឺផ្តាសាយបក្សី។

## ១. ប្រព័ន្ធនៃការចិញ្ចឹមបក្សីជាលក្ខណៈពាណិជ្ជកម្ម នៅព្រះរាជាណាចក្រកម្ពុជា

### ១.១. ការចិញ្ចឹមបក្សីពាក់កណ្តាលលែង ឬលែងដោយសេរី (ឃ្វាលតាមវាល)

ប្រព័ន្ធនៃការចិញ្ចឹមបក្សីពាក់កណ្តាលលែង ឬលែងដោយសេរី (ឃ្វាលតាមវាល) ជាធម្មតាអនុវត្តលើការចិញ្ចឹមទា ដើម្បីឲ្យវាដើររកចំណីដូចជា ស្រូវ ក្តាម ខ្យង ជន្លេន ដង្កូវ និងសត្វល្អិតផ្សេងៗទៀតនៅតាមវាលស្រែ បឹង ត្រពាំង ប្រឡាយ ដោយផ្តល់ចំណីបន្ថែមនៅពេលល្ងាចដូចជា ស្រូវ កន្ទក់ ឬ ចំណីផ្សំ។

ការចិញ្ចឹមទាលែង ធ្វើឲ្យអ្នកចិញ្ចឹមអាចកាត់បន្ថយការចំណាយលើការផ្តល់ចំណី តែផ្ទុយទៅវិញ ការចិញ្ចឹមបែបនេះ អាចធ្វើឲ្យបក្សីងាយនឹងទទួលនូវគ្រោះថ្នាក់ផ្សេងៗដូចជា:

- ចម្លងជំងឺពីបក្សីព្រៃ ឬ ហ្វូងបក្សីដទៃទៀតមានជំងឺ
- ពុលថ្នាំគីមី ឬ
- បាត់បង់បក្សី ដោយការលួច ឬ ចូលជាមួយហ្វូងទាដទៃ



ការចិញ្ចឹមលែងតាមវាល

### ១.២. ការចិញ្ចឹមបក្សីដាក់ទ្រុង

បក្សីចិញ្ចឹមបង្ខាំងឲ្យនៅក្នុងទ្រុង ឬ បរិវេណកំណត់មួយមានរបងព័ទ្ធជុំវិញ អាចកាត់បន្ថយនូវគ្រោះថ្នាក់ពីជំងឺផ្សេងៗ ផ្តល់នូវទិន្នផលខ្ពស់ ក៏ប៉ុន្តែការចិញ្ចឹមបែបនេះទាមទារនូវការផ្តល់ចំណី ទឹកគ្រប់គ្រាន់ និងមានអនាម័យខ្ពស់។ ការចិញ្ចឹមបក្សីដាក់ក្នុងទ្រុង ងាយស្រួលក្នុងការថែទាំ ចាក់វ៉ាក់សាំង និងអនុវត្តវិធានជីវសុវត្ថិភាពមានប្រសិទ្ធភាពខ្ពស់ ដែលធ្វើឲ្យការចិញ្ចឹមទទួលបានជោគជ័យ និងមាននិរន្តភាព។